# ឯកសារសង្ខេបអំពីដៃគូអនុវត្តគម្រោង
# ផ្នែកពិការភាព

## សង្ខេបគម្រោង

អង្គការជនពិការកម្ពុជា កំពុងធ្វើការជាដៃគូជាមួយបណ្តាញអង្គការជនពិការ រដ្ឋាភិបាល វិស័យឯកជន និងមជ្ឈមណ្ឌលស្តារនីតិសម្បទា ដើម្បីចូលរួមចំណែកក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីជនពិការភាព (NDSP ២០១៩-២០២៣) ។ គម្រោងនេះមានគោលបំណងគាំទ្រដល់ការទទួលបាននូវឱកាសការងារកាន់តែប្រសើរឡើងសម្រាប់ស្ត្រីនិងបុរសដែលមានពិការភាព។

## លទ្ធផលរំពឹងទុករបស់គម្រោង

- លើកកម្ពស់ភាពថ្លៃថ្នូរ និងជំនាញដែលជនមានពិការភាពអាចធ្វើបាន។
- លើកកម្ពស់បរិយាប័ន្នជនមានពិការភាពទៅក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ (VT) និងនៅកន្លែងធ្វើការ។
- ពង្រឹងយន្តការការងារ និងប្រព័ន្ធព័ត៌មាន ដែលធ្វើឱ្យការសម្របសម្រួលនិងការបញ្ជូនកាន់តែប្រសើរឡើង។
- លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិជនមានពិការ និងបរិយាប័ន្នការងារតាមរយៈការផ្សព្វផ្សាយ ផែនការយុទ្ធសាស្ត្រជាតិស្តីពីជនមានពិការភាព(NDSP) អនុសញ្ញានៃសិទ្ធិជនមានពិការភាពរបស់អង្គការសហប្រជាជាតិ (UNCRPD) ច្បាប់ស្តីពីកិច្ចការពារ និង លើកកម្ពស់សិទ្ធិជនពិការ យុទ្ធសាស្ត្រអ៊ីនឈាន់ និងផែនការមេអាស៊ាននៃការបញ្ជ្រាបសិទ្ធិជនមានពិការភាព។

## កិច្ចអន្តរាគមន៍សំខាន់ៗ

- បង្កើតកញ្ចប់បណ្តុះបណ្តាលជំនាញទន់ ឯកសារណែនាំបរិយាប័ន្នជនពិការ និងម៉ូឌុលស្ត្រីដែលមានភាពពិការ/អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងផ្តល់ការបណ្តុះបណ្តាលដល់ដៃគូគម្រោង។
- កំណត់អត្តសញ្ញាណអ្នករកការងារធ្វើ ដែលមានពិការភាពហើយបញ្ជូនពួកគេទៅរកឱកាសសេដ្ឋកិច្ចតាមរយៈប្រព័ន្ធបង្អែកកណ្តាល (CRS) កម្មវិធីទិន្នន័យជនពិការ (DDA) និងការិយាល័យសេវាកម្មជនពិការនៅមណ្ឌលស្តារ (PRCs)។

- ការប្រើប្រាស់ប្រភពធនធានរបស់ទីភ្នាក់ងារជាតិមុខរបរ (NEA) ដើម្បីធ្វើការវិភាគទីផ្សារ។
- អនុវត្តកម្មវិធីប្រគល់រង្វាន់ប្រចាំឆ្នាំសម្រាប់និយោជកនៃបរិយាបន្នពិការភាពនៃវិស័យការងារ ។
- ការអភិវឌ្ឍសហគមន៍អនុវត្តនៃ អង្គការជនពិការភាពថ្នាក់ជាតិលើ និយោជកនៃបរិយាបន្នពិការភាពក្នុងវិស័យការងារ។
- យុទ្ធនាការលើកកម្ពស់ការយល់ដឹងរបស់សហគមន៍ស្ដីពីការអនុវត្តបរិយាបន្នពិការភាព។

**កិច្ចអន្តរាគមន៍ជាពិសេស ចំពោះការទប់ស្កាត់ការរីករាលមេរោគ កូវីដ-១៩**

- ចូលរួមពិភាក្សាក្នុងការបង្កើតសម្ភារព័ត៌មាន ការអប់រំ និងផ្សព្វផ្សាយលើជំងឺកូវីដ-១៩
- ផ្សព្វផ្សាយសារអប់រំអំពីវិធីសាស្ត្រការពារជំងឺកូវីដ-១៩ តាមទំព័រហ្វេសប៊ុក និងវិទ្យុសំឡេងជនពិការ
- ផ្សព្វផ្សាយបន្តវិឌីអូអប់រំអំពីវិធីសាស្ត្រការពារជំងឺកូវីដ-១៩ នៅតាមទំព័រហ្វេសប៊ុករបស់អង្គការជនពិការកម្ពុជា។
- សហការជាមួយដៃគូគម្រោង ក្នុងការបញ្ជូនអ្នកបកប្រែភាសាសញ្ញា ទៅបកប្រែនៅ សន្និសិទសារព័ត៌មានប្រចាំសប្ដាហ៍ ដែលផ្សាយផ្ទាល់តាមរយៈសារព័ត៌មាន Fresh News និងស្ថាប័នសារព័ត៌មានផ្សេងៗទៀត។

**ក្រុមគោលដៅ**

- ក្រុមគោលដៅផ្ទាល់៖ ជនមានពិការភាព និយោជក អង្គការជនពិការ ឬអង្គការតំណាងជនពិការ ទីភ្នាក់ងារមុខរបរ (NEA) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT) វិទ្យាស្ថានពហុបច្ចេកទេសខេត្ត ឬសាលាអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ(ប្រសិនបើខេត្តនៅក្រោមការគ្រប់គ្រងរបស់មន្ទីការងារ) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY)  និង មណ្ឌលស្តារ (PRCs).
- ក្រុមគោលដៅប្រយោល៖ គ្រួសារជនមានពិការភាព

**តំបន់គោលដៅ**

ខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្តបាត់ដំបង និងខេត្តក្រចេះ

**ដៃគូអនុវត្តគម្រោង**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY)  ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT) ទីភ្នាក់ងារមុខរបរ (NEA) ក្រុមប្រឹក្សាសកម្មភាពជនពិការ  (DAC) អង្គការជនពិការកម្ពុជា និងអង្គការបន្ទាយស្រី

**រយៈពេលអនុវត្តគម្រោង**

ខែកញ្ញា ឆ្នាំ ២០១៩ ដល់ ខែមិថុនា ឆ្នាំ ២០២១

**ថវិកាគម្រោង**

ថវិកាសរុប៖ ៥២៧,០០០ ដុល្លារអូស្ត្រាលី (ថវិកាពី ACCESS៖ ៥០៥,៨៦១ ដុល្លារអូស្ត្រាលី

| ព័ត៌មានទំនាក់ទំនង | |
|---|---|
| អង្គការជនពិការកម្ពុជា (CDPO)<br>លោកស្រី **ម៉ាក់ ម៉ូនីកា**<br>នាយិកាប្រតិបត្តិ<br>ទូរស័ព្ទ៖ (៨៥៥) ១៦ / ៧៧ ៨០០ ៥៧២<br>អ៊ីម៉ែល៖ monika.mak@cdpo.org / director@cdpo.org | កម្មវិធី ACCESS<br>លោក **ជូ វិវឌ្ឍន៍**<br>ប្រធានផ្នែកពិការភាព<br>ទូរស័ព្ទ៖ (៨៥៥) ១២ ៩១៥ ៦៧៤<br>អ៊ីម៉ែល៖ vivath.ch@accesscambodia.org |

គម្រោងនេះឧបត្ថម្ភដោយរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី សហប្រតិបត្តិការអូស្ត្រាលី-កម្ពុជា ដើម្បីសេវាប្រកបដោយនិរន្តរភាព និងសមធម៌ (ACCESS)។

ខែឧសភា ឆ្នាំ២០២០